ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ១៣ រោច ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម Pablo Kang ឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលីប្រចាំកម្ពុជា

នៅរសៀលថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គ-បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Pablo Kang ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលីប្រចាំកម្ពុជា ។

ក្នុងជំនួបពិភាក្សានោះ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនអូស្ត្រាលី ដែលបានផ្តល់ហិរញ្ញប្បទានឥតសំណងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ជាពិសេស លើវិស័យអប់រំ សុខាភិបាល កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងអភិបាលកិច្ច ។ ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងអូស្ត្រាលី ត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ ហើយបាននាំមកនូវលទ្ធផលប្រកបដោយផ្លែផ្កា ។ ជាក់ស្តែង, ក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ រដ្ឋាភិបាលអូស្ត្រាលី ក៏បានជួយបន្ថែមទៀតដល់វិស័យសុខាភិបាល ក៏ដូចជាបានតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួនសំដៅជួយស្តារសម្បទាសេដ្ឋកិច្ចកម្ពុជាឡើងវិញ ។

ឯកឧត្តមឯកអគ្គរដ្ឋទូត Pablo Kang បានវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលមកទល់ពេលនេះសម្រេចបានលទ្ធផលល្អប្រសើរក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ រដ្ឋាភិបាលអូស្ត្រាលីនឹងបន្តជួយឧបត្ថម្ភគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺនេះ តាមរយៈការផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់អនុវត្តគម្រោង ឬកម្មវិធីនានា ដែលជួយកែលម្អគុណភាពនៃសេវាសុខាភិបាល, លើកកម្ពស់សន្តិសុខស្បៀង, និងកែលម្អជីវភាពរបស់ប្រជាជន ជាពិសេស ប្រជាជននៅជនបទ អ្នកបាត់បង់ការងារនៅទីក្រុង ស្ត្រីរងគ្រោះដោយសារអំពើហឹង្សា និងជនពិការ ។ បន្ថែមលើនេះ, ក៏មានគម្រោងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនៅជនបទផងដែរ មានដូចជា ប្រព័ន្ធធារាសាស្ត្រ បណ្តាញទឹកស្អាត និងបណ្តាញចែកចាយអគ្គិសនី ជាដើម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងនូវអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលីដែលបន្តជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងគ្រាដ៏លំបាកនេះ និងបានចូលរួមយ៉ាងសកម្មនិងទាន់ពេលវេលាក្នុងបេសកកម្មប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា ។ បច្ចុប្បន្ន, ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់លើជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចស្ថានភាពនៃធុរកិច្ច រួមទាំងវិនិយោគពីបរទេស ដែលកំពុងទទួលរងគ្រោះដោយសារជំងឺកូវីដ-១៩ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសេចក្តីសោមនស្សរីករាយក្នុងការសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីកៀរគរធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តគោលនយោបាយប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច, និងគាំពារសង្គម ជាពិសេស ផ្តោតលើការជួយដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ។

ជាទីបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណជាថ្មីម្តងទៀតដល់រដ្ឋាភិបាលនិងប្រជាជនអូស្ត្រាលីដែលបានរួមវិភាគទានដ៏ថ្លៃថ្លាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅកម្ពុជា ។ ភាគីទាំងពីរនឹងបន្តពូនជ្រុំមូលដ្ឋានគ្រឹះនៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដែលមានស្រាប់ ឲ្យកាន់តែរឹងមាំថែមទៀត ។